# សំណើប្រជាមតិ 30

# ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 30 ★

*សារមួយពីសម្ព័ន្ធអ្នកបោះឆ្នោតស្ត្រីនៃរដ្ឋកាលីហ្វ័រញ៉ា និងគ្រូបង្រៀននៃរដ្ឋកាលីហ្វ័រញ៉ា និងអ្នកមានវិជ្ជាជីវៈពង្រឹងការអនុវត្តច្បាប់*

ជូនចំពោះសមាជិកនៅរដ្ឋកាលីហ្វ័រញ៉ា,

បន្ទាប់ពីការកាត់អស់រយៈពេលប៉ុន្មានឆ្នាំមកនេះ សាលារៀន សាកលវិទ្យាល័យរដ្ឋ និងសេវាសុវត្ថិភាពសាធារណៈរបស់រដ្ឋកាលីហ្វ័រញ៉ាស្ថិតក្នុងចំណុចប្រេះស្រាំ។

គ្រាន់តែក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ សាលារៀនរបស់យើងទទួលរងការកាត់បន្ថយចំនួន $20 ពីរពាន់កោដិដុល្លារ ខ្វះគ្រូបង្រៀនជាង 30,000 នាក់និងចំនួនសិស្សច្រើនក្នុងមួយថ្នាក់ ដែលស្ថិតក្នុងចំណោមចំនួនច្រើនជាងគេបំផុតនៅក្នុងប្រទេស។ កុមាររបស់យើង សមនឹងទទួលបានថ្នាក់រៀនកាន់តែប្រសើរជាងនេះ។

ដល់ពេលដែលត្រូវបញ្ចេញមតិ និងរក្សាឲ្យរដ្ឋកាលីហ្វ័រញ៉ាស្ថិតនៅក្នុងគន្លងដើមវិញហើយ។

សំណើប្រជាមតិលេខ 30 ច្បាប់ការពារសុវត្ថិភាពសាលារៀន និងទីសាធារណៈតាមមូលដ្ឋាន ត្រូវបានគាំទ្រដោយអភិបាល Jerry Brown សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី និងក្រុមអ្នកដឹកនាំចំរុះទូទាំងប្រទេស ដែលមកពីផ្នែកអប់រំផ្នែកពង្រឹងការអនុវត្តច្បាប់ និងអាជីវកម្ម។

*មានការគាំទ្រទូលំទូលាយចំពោះសំណើប្រជាមតិលេខ 30 ពីព្រោះវាជាការផ្ដួចផ្ដើមតែមួយគត់ ដែលនឹងការពារសាលារៀន និងសុវត្ថិភាពថវិកា និងជួយដោះស្រាយភាពរញ៉េរញ៉ៃនៃគម្រោងថវិកាដ៏រ៉ាំរ៉ៃរបស់រដ្ឋ៖*

- *ទប់ស្កាត់ការកាត់ពីសាលារៀនយ៉ាងច្រើន។* បើគ្មានសំណើប្រជាមតិលេខ30 ទេ សាលារៀន និងមហាវិទ្យាល័យរបស់យើង ប្រឈមនឹងការកាត់ដ៏ច្រើនគឺ $6 ប្រាំមួយរយកោដិ បន្ថែមទៀតនៅឆ្នាំនេះ។ សំណើប្រជាមតិលេខ 30 គឺជាការផ្ដួចផ្ដើម តែមួយគត់ ដែលទប់ស្កាត់ការកាត់ទាំងនោះ និងផ្ដល់ថវិកាថ្មីៗជាច្រើនកោដិដុល្លារ សម្រាប់សាលារៀនរបស់យើងដោយចាប់ផ្ដើមពីឆ្នាំនេះតទៅ គឺថវិកាដែលអាចចំណាយលើ ការធ្វើឲ្យចំនួនសិស្សក្នុងមួយថ្នាក់កាន់តែតិចជាងមុន បន្ទាន់សម័យសៀវភៅសិស្ស និងការជួលគ្រូឲ្យមកបង្រៀនវិញ។
- *ធានាថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន។* សំណើប្រជាមតិលេខ 30 គឺជាវិធានការ តែមួយគត់ ដែលស្ថាបនាការធានាមួយ សម្រាប់ថវិកាខាងសុវត្ថិភាពសាធារណៈនៅក្នុងធម្មនុញ្ញរដ្ឋរបស់យើងដែលគ្មាននរណាអាចប៉ះពាល់វាបានឡើយ បើគ្មានការយល់ព្រមពីអ្នកបោះឆ្នោតទេនោះ។ សំណើប្រជាមតិលេខ 30 រក្សាឲ្យអ្វីៗទាំងអស់មានតម្លាភាពជានិច្ច។ .
- *ជួយធ្វើឲ្យគម្រោងថវិកាមានតុល្យភាព។* សំណើប្រជាមតិលេខ 30 ធ្វើឲ្យគម្រោងថវិការបស់យើងមានតុល្យភាព និងជួយទូទាត់បំណុលរបស់រដ្ឋកាលីហ្វ័រញ៉ា ដែលបង្កើតឡើងដោយសារការបំភាន់ និងការខ្ចីច្រើនឆ្នាំ។ វាគឺជា ជំហានដ៏សំខាន់មួយ ក្នុងការបញ្ឈប់ កង្វះថវិកាដែលញាំញីរដ្ឋកាលីហ្វ័រញ៉ា។

ដើម្បីការពារសាលារៀន និងសុវត្ថិភាព សំណើប្រជាមតិលេខ 30 បានបង្កើនជាបណ្ដោះអាសន្ន នូវពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន ទៅលើអ្នករកប្រាក់ចំណូលខ្ពស់បំផុតគឺប្ដីប្រពន្ធដែលមានប្រាក់ចំណូលលើស $500,000 ក្នុងមួយឆ្នាំ និងស្ថាបនាពន្ធទំនិញលក់ចេញនៅត្រឹមអត្រាមួយ ដែលទាបជាងពីឆ្នាំមុន។

*ពន្ធរបស់សំណើប្រជាមតិលេខ 30 ត្រូវបានធ្វើឲ្យមានតុល្យភាពជាបណ្ដោះអាសន្ន និងមានភាពចាំបាច់ក្នុងការការពារសាលារៀន និងសុវត្ថិភាព ៖*

- *មានតែអ្នករកប្រាក់ចំណូលខ្ពស់បំផុតប៉ុណ្ណោះ ដែលត្រូវបង់ពន្ធប្រាក់ចំណូលច្រើនជាងមុន៖* សំណើប្រជាមតិលេខ 30 ស្នើឲ្យអ្នកដែលរកប្រាក់ចំណូលបានច្រើនជាងគេ បង់ពន្ធប្រាក់ចំណូលច្រើនជាងមុន។ ប្ដីប្រពន្ធដែលរកប្រាក់ចំណូលបានទាបជាង $500,000 ក្នុងមួយឆ្នាំ នឹងមិនត្រូវបង់ពន្ធប្រាក់ចំណូលបន្ថែមឡើយ។
- *ប្រាក់ចំណូលថ្មីទាំងអស់មានលក្ខណៈជាបណ្ដោះអាសន្ន៖* ពន្ធរបស់សំណើប្រជាមតិលេខ 30 មានលក្ខណៈជាបណ្ដោះអាសន្ន ការផ្ដួចផ្ដើមនេះ មិនអាចកែប្រែដោយការបោះឆ្នោតរបស់ប្រជាជនបានឡើយ។ អ្នករកប្រាក់ចំណូលបានខ្ពស់ជាងគេ នឹងត្រូវបង់ច្រើនជាងមុនរយៈពេលប្រាំពីរឆ្នាំ។ ខចែងអំពីពន្ធទំនិញលក់ចេញ នឹងមានសុពលភាពរយៈពេលបួនឆ្នាំ។
- *ថវិកាចូលទៅក្នុងគណនីពិសេស ដែលអង្គនីតិបញ្ញត្តិមិនអាចប៉ះពាល់បាន៖* ថវិកាដែលបានបង្កើនសម្រាប់សាលារៀន ត្រូវបានចាត់ចែងចូលទៅក្នុងថវិកាពិសេស ដែលអង្គនីតិបញ្ញត្តិមិនអាចប៉ះពាល់បាន ហើយមិនអាចប្រើសម្រាប់ការិយាធិបតេយ្យរបស់រដ្ឋបានឡើយ។
- *សំណើប្រជាមតិលេខ 30 អនុញ្ញាតឲ្យមានសវនកម្មមានសិទ្ធិ៖* សវនកម្មមានសិទ្ធិ និងឯករាជ្យ និងធានាថា ថវិកាត្រូវបានចំណាយ តែម្យ៉ាងគត់ សម្រាប់សាលារៀន និងសុវត្ថិភាពសាធារណៈ។

ចូលរួមជាមួយសម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី និងគ្រូបង្រៀនរដ្ឋកាលីហ្វ័រញ៉ា និងអ្នកវិជ្ជាជីវៈសុវត្ថិភាពសាធារណៈ។

បោះឆ្នោត បាទ/ចាសលើសំណើប្រជាមតិលេខ 30។

*ក្រោកឈរដើម្បីសាលារៀននិងសុវត្ថិភាព សាធារណៈ។*

ស្វែងយល់ថែមទៀត សូមទស្សនាគេហទំព័រ *YesOnProp30.com.*

**JENNIFER A. WAGGONER**, ប្រធាន
សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា

**DEAN E. VOGEL**, ប្រធាន
សមាគមគ្រូបង្រៀនកាលីហ្វ័រញ៉ា

**KEITH ROYAL**, ប្រធាន
សមាគមតម្រួតតំបន់រដ្ឋកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 30 ★

អ្នកគាំទ្រសំណើប្រជាមតិលេខ 30 និយាយថា យើងត្រូវតែយល់ព្រមទៅលើការបង្កើនពន្ធដ៏ច្រើន ពុំដូច្នោះទេថវិកាសម្រាប់សាលារៀននឹងត្រូវកាត់បន្ថយ។

យើងទាំងអស់គ្នាចង់បានសាលារៀនដ៏ប្រសើរនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាប៉ុន្តែការបង្កើនពន្ធមិនមែនជាវិធីតែមួយក្នុងការសម្រេចកិច្ចការនេះឡើយ។

អ្នកនយោបាយ ចង់បង្កើនពន្ធជំនួសឲ្យការធ្វើឲ្យមានប្រសិទ្ធភាពកម្មវិធីរាប់ពាន់ដែលផ្ដល់ថវិកាដោយរដ្ឋ ការិយាធិបតេយ្យ និងការខ្ជះខ្ជាយដ៏ច្រើនសន្ធឹកសន្ធាប់។

សូមមើលអ្វីដែលពួកគេទើបនឹងបានធ្វើរួច៖ អ្នកនយោបាយបានអនុញ្ញាតជិត *$5 ប្រាំរយកោដិ* នៃសញ្ញាប័ណ្ណរដ្ឋកាលីហ្វ័រញ៉ាសម្រាប់ "រថភ្លើងលឿនមិនទៅកន្លែងណាមួយ" ដែលអ្នកជាប់ពន្ធទាំងឡាយត្រូវចំណាយ $380 លានក្នុងមួយឆ្នាំ។ យើងនាំគ្នាប្រើថវិកាទាំងនោះសម្រាប់សាលារៀនវិញ!

តែជំនួសវិញអ្នកនយោបាយឱ្យយើងនូវជំរើសខុស—តំឡើងពន្ធលក់ដូររហូតដល់ $1 មួយរយកោដិ ក្នុងមួយឆ្នាំហើយតំឡើងពន្ធប្រាក់ចំណូលពីពាណិជ្ជកម្មខ្នាតតូច ឬកាត់សាលារៀន។

សំណើប្រជាមតិលេខ 30 មិនដូចអ្វីដែលមើលឃើញទេ៖ វាមិនធានាដល់ការផ្ដល់ថវិកាថ្មីសម្រាប់ថ្នាក់រៀន សូម្បីតែមួយដុល្លារឡើយ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាអនុញ្ញាតឲ្យអ្នកនយោបាយយកថវិកា ដែលបច្ចុប្បន្ននេះត្រូវបានរក្សាទុកដោយឡែកសម្រាប់វិស័យអប់រំហើយចំណាយ វាទៅលើកម្មវិធីផ្សេងៗ។ យើងគ្មានថ្ងៃដឹងថាថវិកានោះទៅខាងណា ឲ្យប្រាកដនោះឡើយ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាផ្ដល់ឱ្យអ្នកនយោបាយនៅ Sacramento សន្លឹកសែកចំហមួយដោយគ្មានការតំរូវថវិកា សោធននិវត្តន៍ ឬការកែទម្រង់ផ្នែកអប់រំ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាធ្វើឱ្យឈឺចាប់ដល់ពាណិជ្ជកម្មខ្នាតតូច និងសំឡាប់ការងារ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ គឺវាគ្រាន់តែផ្ដល់ប្រាក់ច្រើនថែមទៀតដល់អ្នកនយោបាយនៅ Sacramento ដើម្បីបន្តចំណាយថែមទៀត។

កុំយល់ខុស សំណើប្រជាមតិលេខ 30 មិនដូចអ្វីដែលមើលឃើញទេ។ វាគ្រាន់តែជាលេស សម្រាប់ឲ្យអ្នកនយោបាយនៅក្រុងសាក្រាម៉ិនតូ យកថវិការបស់អ្នកកាន់តែច្រើនប៉ុណ្ណោះ ខណៈធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ច និងមិនបានធ្វើអ្វីដើម្បីជួយដល់វិស័យអប់រំសោះ។

ពលរដ្ឋកាលីហ្វ័រញ៉ា សុទ្ធតែឆ្លាតៗ មិនល្ងង់ទេ៖ *បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30!*

**JOEL FOX**, ប្រធាន
គណៈកម្មការសកម្មភាពពាណិជ្ជកម្មខ្នាតតូច

**JOHN KABATECK**, នាយកប្រតិបត្តិ
សហព័ន្ធជាតិនៃពាណិជកម្មឯករាជ្យ/ កាលីហ្វ័រញ៉ា

**KENNETH PAYNE**, ប្រធាន
សមាគមអ្នកជាប់ពន្ធ Sacramento



*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# សំណើប្រជាមតិ 30

## ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ 30 ★

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាគ្រាន់តែជា "ល្បែងបោកបញ្ឆោត" នយោបាយក្នុងទឹកប្រាក់ $50 ប្រាំពាន់កោដិ ប៉ុណ្ណោះ ប៉ុន្តែមិនបានធានាដល់ការផ្ដល់ថវិកាថ្មីសម្រាប់សាលារៀនឡើយ។

អ្នកនយោបាយដែលនៅពីក្រោយសំណើប្រជាមតិលេខ 30 ចង់ឲ្យយើងជឿថា ប្រសិនបើអ្នកបោះឆ្នោតយល់ព្រមចំពោះការបង្កើនពន្ធដ៏ច្រើន ក្នុងរយៈពេលប្រាំពីរឆ្នាំ តាមសំណើប្រជាមតិលេខ 30 នោះ ថវិកាថ្មីនឹងបានទៅដល់ថ្នាក់រៀនជាច្រើន។ គ្មានអ្វីអាចបន្ថែមលើសពីការពិតទេ។

សំណើប្រជាមតិលេខ 30 អនុញ្ញាតឲ្យអ្នកនយោបាយលេង "ល្បែងបោកបញ្ឆោត" ជំនួសឲ្យការផ្ដល់ថវិកាថ្មីដល់សាលារៀន៖

- ពួកគេអាចយកថវិកាដែលមានស្រាប់សម្រាប់សាលារៀន ហើយប្រើវាសម្រាប់គោលបំណងផ្សេងៗ រួចហើយជំនួសថវិកានោះជាមួយថវិកាដែលបានមកពីពន្ធថ្មី។ ពួកគេប្រើដៃម្ខាងយកចេញ ហើយប្រើដៃម្ខាងទៀតដាក់មកវិញ។ មិនថាអ្នកយល់យ៉ាងណាឡើយ សំណើប្រជាមតិលេខ 30 មិនបានធានាដល់ការផ្ដល់ថវិកាថ្មីសម្រាប់សាលារៀន សូម្បីតែមួយកាក់មួយសេនឡើយ។
- អ្នកអប់រំជាច្រើនបានផ្សព្វផ្សាយអំពីគុណវិបត្តិនេះ ហើយសូម្បីតែសមាគមគណៈកម្មការសាលារៀននៅរដ្ឋកាលីហ្វ័រញ៉ាបានថ្លែងថា " ...ការផ្ដើមប្រជាសិទ្ធិរបស់អភិបាលមិនបានផ្ដល់ថវិកាថ្មីសម្រាប់សាលារៀនឡើយ។" (20 ឧសភា 2012)។
- កាសែតឈ្មោះ Wall Street បានរកឃើញគុណវិបត្តិដូចគ្នានេះ ដោយបានថ្លែងថា "អភិបាលរដ្ឋកាលីហ្វ័រញ៉ា លោក Jerry Brown កំពុងព្យាយាមលក់កំណើនពន្ធរបស់លោក ទៅឲ្យអ្នកបោះឆ្នោតនៅខែវិច្ឆិកានេះ ដោយនិយាយថា វានឹងបានទៅដល់សាលារៀនទាំងឡាយ។ អាថ៌កំបាំងតូចដ៏កខ្វក់គឺថា ប្រាក់ចំណូលថ្មី នឹងត្រូវការ ដើម្បីបំពេញដល់ប្រាក់សោធននិវត្តន៍របស់គ្រូបង្រៀនដែលមិនទាន់បានសង។" វិចារណកថារបស់កាសែត Wall Street ចេញផ្សាយថ្ងៃទី 22 ខែមេសា ឆ្នាំ 2012។
- សូម្បីតែចំណងជើងផ្លូវការ និងសេចក្ដីសង្ខេបនៃសំណើប្រជាមតិលេខ 30 និយាយថា ថវិកាអាចត្រូវបានប្រើសម្រាប់ "... ទូទាត់សម្រាប់ការប្ដេជ្ញាចំណាយផ្សេងៗ។"

លើសពីនេះទៀត ពុំមានលក្ខខណ្ឌតម្រូវ ឬការធានាថា ថវិកាច្រើនជាងមុនណាមួយពិតជាបានទៅដល់ថ្នាក់រៀនឡើយ ហើយពុំមានអ្វីមួយនៅក្នុងសំណើប្រជាមតិលេខ 30 ធ្វើកំណែទម្រង់ប្រព័ន្ធអប់រំរបស់យើង ដើម្បីកាត់បន្ថយការខ្ជះខ្ជាយ លុបបំបាត់ការិយាធិបតេយ្យ ឬកាត់បន្ថយបន្ទុកចំណាយរដ្ឋបាលឡើយ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30— គ្មានកំណែទម្រង់ទេ។

អ្នកនយោបាយ និងផលប្រយោជន៍ពិសេសនៅពីក្រោយ សំណើប្រជាមតិលេខ 30 ចង់បង្កើនពន្ធ ដើម្បីទូទាត់ចំណាយដែលមិនអាចគ្រប់គ្រងបានរបស់ពួកគេ ប៉ុន្តែបដិសេធមិនព្រមអនុម័តកំណែទម្រង់ដ៏មានន័យ ៖

- ផលប្រយោជន៍ពិសេស និងអ្នកនយោបាយដែលពួកគេគ្រប់គ្រង បានធ្វើឲ្យរាំងស្ទះដល់កំណែទម្រង់ប្រាក់សោធននិវត្តន៍។ យើងមាន $500 ប្រាំរយពាន់កោដិ នៅក្នុងបំណុលសោធននិវត្តន៍ ដែលមិនទាន់បានផ្ដល់ថវិកានៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ហើយអ្នកនយោបាយនៅតែបដិសេធមិនព្រមអនុម័តកំណែទម្រង់ជាក់ស្ដែង។
- ក្រុមមនុស្សតែមួយនេះ បានធ្វើឲ្យរាំងស្ទះដល់កំណែទម្រង់គម្រោងថវិកា។ អ្នកនយោបាយបន្តចំណាយច្រើនជាងថវិកាដែលរដ្ឋមាន។ សំណើប្រជាមតិទី 30 បានប្រគល់ការប្រព្រឹត្តដ៏គ្រោះថ្នាក់នេះ ដោយផ្ដល់ឲ្យពួកគេនូវថវិការាប់ពាន់លានដុល្លារថែមទៀត ដើម្បីចំណាយដោយគ្មានកំណែទម្រង់ គ្មានការធានាថា ថវិកានឹងមិនខ្ជះខ្ជាយ ឬការធានាថា ថវិកានោះនឹងពិតជាបានទៅដល់ថ្នាក់រៀន។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 — បញ្ឈប់ការគំរាមកំហែងពីអ្នកនយោបាយ។

អភិបាល អ្នកនយោបាយ និងផលប្រយោជន៍ពិសេសនៅពីក្រោយសំណើប្រជាមតិលេខ 30 គំរាមកំហែងដល់អ្នកបោះឆ្នោត។ ពួកគេនិយាយថា "បោះឆ្នោតឲ្យការបង្កើនពន្ធដ៏ច្រើនរបស់យើង ពុំដូច្នោះទេ យើងនឹងដកវាចេញពីសាលារៀន" ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ ពួកគេបដិសេធមិនព្រមកែទម្រង់ប្រព័ន្ធអប់រំ ឬសោធននិវត្តន៍ដើម្បីសន្សំសំចៃថវិកាឡើយ។

យើងត្រូវធ្វើឲ្យមានកំណើនសេដ្ឋកិច្ចរបស់យើង ដើម្បីបង្កើតការងារ និងកាត់បន្ថយការខ្ជះខ្ជាយ បោសសម្អាតរដ្ឋាភិបាល កែទម្រង់ដំណើរការគម្រោងថវិការបស់យើង និងធ្វើឲ្យអ្នកនយោបាយទទួលខុសត្រូវ ជំនួសឲ្យការយល់ព្រមចំពោះកំណើនពន្ធ $50 ប្រាំពាន់កោដិ លើអាជីវកម្មខ្នាតតូច និងគ្រួសារការងារ ដែលមិនផ្ដល់គណនេយ្យភាពណាមួយ ឬធានាការផ្ដល់ថវិកាថ្មីសម្រាប់សាលារៀន។

មិនយល់ព្រមចំពោះសំណើប្រជាមតិលេខ 30 — កំណែទម្រង់ និងការងារជាចម្បង មិនមែនពន្ធកាន់តែខ្ពស់ទេ។

**JON COUPAL**, ប្រធាន
សមាគមអ្នកជាប់ពន្ធ Howard Jarvis

**TOM BOGETICH**, នាយកប្រតិបត្តិ (ចូលនិវត្តន៍)
ក្រុមប្រឹក្សាអប់រំកាលីហ្វ័រញ៉ា

**DOUG BOYD**, សមាជិក
ក្រុមប្រឹក្សាអប់រំខោនធី Los Angeles

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 30 ★

ក្រោយពីការកាត់អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកដល់ពេលដែលត្រូវគូសបន្ទាត់មួយ ដើម្បីការពារសាលារៀន និងសុវត្ថិភាពសាធារណៈតាមមូលដ្ឋានហើយ។

ការគ្រប់គ្រងសារពើពន្ធដ៏រឹងមាំរបស់ សំណើប្រជាមតិទី 30 ធានាថា ថវិកាត្រូវបាន ចំណាយ តែម្យ៉ាងគត់ ទៅលើសាលារៀន និងសុវត្ថិភាពសាធារណៈ៖

- ប្រាក់ចំណូលត្រូវបានធានានៅក្នុងធម្មនុញ្ញ ថានឹងចូលទៅក្នុងគណនីពិសេសមួយសម្រាប់សាលារៀន ដែល*អង្គនីតិបញ្ញត្តិមិនអាចប៉ះពាល់បាន*។
- ថវិកានឹងត្រូវបានធ្វើសវនកម្ម *រៀងរាល់ឆ្នាំ* ហើយមិនអាចចំណាយទៅលើការគ្រប់គ្រងរដ្ឋបាល ឬការិយាធិបតេយ្យរបស់ក្រុងសាក្រាម៉ិនតូឡើយ។
- សំណើប្រជាមតិលេខ 30 អនុញ្ញាតឲ្យមានបណ្ដឹងរឿងព្រហ្មទណ្ឌ ចំពោះការប្រើថវិកាខុស។

កូនៗរបស់យើងសមតែទទួលបានថ្នាក់រៀនកាន់តែប្រសើរ ជាជាងថ្នាក់រៀនដែលមានចំនួនសិស្សច្រើនជាងគេបំផុតនៅក្នុងប្រទេស។ សំណើប្រជាមតិលេខ 30 ស្នើឲ្យអ្នកមានទ្រព្យធនច្រើន បង់ចំណែកស្មើ របស់គេ ដើម្បីរក្សាឲ្យថ្នាក់រៀនបើកចំហនិងមានតម្លាភាព។

- ទប់ស្កាត់ការកាត់បន្ថយថវិកាច្រើនពីសាលារៀនឆ្នាំនេះ៖ សំណើប្រជាមតិលេខ 30 គឺជាការផ្ដួចផ្ដើមតែមួយគត់ ដែលទប់ស្កាត់ថវិកាចំនួន $6 ប្រាំមួយរយកោដិ នៅក្នុងការកាត់ដោយស្វ័យប្រវត្តិពីសាលារៀន និងសាកលវិទ្យាល័យនៅឆ្នាំនេះ។ បើគ្មានសំណើប្រជាមតិលេខ 30 ទេ យើងប្រឈមនឹងឆ្នាំសិក្សាកាន់តែខ្លី ការបញ្ឈប់គ្រូបង្រៀនបណ្ដោះអាសន្ន និងកំណើនការសិក្សាឡើង ឬចុះនៅក្នុងឆ្នាំនេះ។
- ផ្ដល់ថវិការាប់ពាន់លាននៅក្នុងការផ្ដល់ថវិកាថ្មីដល់សាលារៀន៖ សំណើប្រជាមតិលេខ 30 ផ្ដល់ថវិការាប់ពាន់លានបន្ថែមទៀត ដើម្បីកាត់បន្ថយចំនួនសិស្សច្រើនក្នុងមួយថ្នាក់ និងស្ដារកម្មវិធីទាំងឡាយដូចជា សិល្បៈ និងការអប់រំកាយជាដើម។
- ការពារសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន៖ សំណើប្រជាមតិលេខ 30 ធានាដល់ការផ្ដល់ថវិកាដល់សុវត្ថិភាពសាធារណៈតាមមូលដ្ឋាន នៅក្នុងរដ្ឋធម្មនុញ្ញ និងជួយសន្សំសំចៃថវិការាប់ពាន់លាន នៅក្នុងខ្ទង់ចំណាយលើពន្ធនាគារនាពេលអនាគត។
- ជួយធ្វើឲ្យគម្រោងថវិកាមានតុល្យភាព៖ សំណើប្រជាមតិលេខ 30 គឺជាផ្នែកនៃដំណោះស្រាយរយៈពេលវែង ដើម្បីធ្វើឲ្យគម្រោងថវិការដ្ឋមានតុល្យភាព។

គ្រូបង្រៀន អ្នកពង្រឹងការអនុវត្តច្បាប់ អ្នកដឹកនាំអាជីវកម្ម និងលោកអភិបាល Jerry Brown ទាំងអស់គ្នាគាំទ្រដល់សំណើប្រជាមតិលេខ 30 ពីព្រោះវាគឺជាវិធានការតែមួយគត់ ដែលនឹងដាក់រដ្ឋកាលីហ្វ័រញ៉ានៅលើផ្លូវមួយ ឆ្ពោះទៅរកការស្ដារឡើងវិញ។

*ស្វែងយល់បន្ថែមទៀតតាមអាសយដ្ឋាន www.YesOnProp30.com ។*

**JENNIFER A. WAGGONER**, ប្រធាន
សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា

**JOSHUA PECHTHALT**, ប្រធាន
សហព័ន្ធគ្រូបង្រៀនរដ្ឋកាលីហ្វ័រញ៉ា

**SCOTT R. SEAMAN**, ប្រធាន
សមាគមនាយកប៉ូលិសកាលីហ្វ័រញ៉ា